# តើអ្នកព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកឬ?

**ពលរដ្ឋខ្លះមានអារម្មណ៍ថាមិនមានសុវត្ថិភាពគ្រប់គ្រាន់ឡើយ ក្នុងការឲ្យព័ត៌មានលម្អិតរបស់ពួកគេផ្សព្វផ្សាយជាសាធារណៈនៅលើបញ្ជីបោះឆ្នោត ប៉ុន្តែនេះមិនមានន័យថាពួកគេបាត់បត់សិទ្ធិបោះឆ្នោតឡើយ។**

ប្រសិនបើអ្នកមានក្តីកង្វល់អំពីសុវត្ថិភាពរបស់អ្នក ឬគ្រួសាររបស់អ្នក អ្នកអាចស្នើសុំឲ្យដាក់ឈ្មោះលើបញ្ជីសម្ងាត់មិនផ្សព្វផ្សាយបាន។ ព័ត៌មានលម្អិតនៃការចុះឈ្មោះបោះឆ្នោតរបស់អ្នកនឹងត្រូវបានរក្សាទុកដោយសុវត្ថិភាព ហើយមិនត្រូវបានផ្តល់ឲ្យនរណាម្នាក់ឡើយ។

# ព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកឬ?

ELECTORAL COMMISSION
TE KAITIAKI TAKE KŌWHIRI



**vote.nz**
**0800 36 76 56**

ROE47B 23/04/20_Khmer

## ចុះប្រសិនបើព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់ខ្ញុំផ្លាស់ប្ដូរ?

នៅពេលអ្នកមានឈ្មោះលើបញ្ជីមិនផ្សព្វផ្សាយ អ្នកត្រូវផ្ដល់ដំណឹងដល់យើង ប្រសិនបើព័ត៌មានលម្អិតណាមួយអំពីការចុះឈ្មោះបោះឆ្នោតរបស់អ្នក មានការផ្លាស់ប្ដូរ ដូចជាឈ្មោះ ឬអាសយដ្ឋានរបស់អ្នកជាដើម។ អ្នកអាចធ្វើដូច្នោះបានដោយបំពេញទម្រង់បែបបទនៃការចុះឈ្មោះបោះឆ្នោតថ្មី ហើយប្រគល់វាមកយើងវិញ។ អ្នកក៏អាចស្នើសុំត្រឡប់ទៅដាក់ឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតដែលមានផ្សព្វផ្សាយសាធារណៈផងដែរ ប្រសិនបើស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកមានការផ្លាស់ប្ដូរ។

សូមទាក់ទងមន្ត្រីចុះបញ្ជីអ្នកបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក ឬផ្ញើអ៊ីមែលមកយើងតាមរយៈ **unpublished.roll@elections.govt.nz** ប្រសិនបើអ្នកត្រូវធ្វើការផ្លាស់ប្ដូរណាមួយ។

## តើខ្ញុំបោះឆ្នោតដោយរបៀបណា នៅពេលខ្ញុំមានឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនផ្សព្វផ្សាយនេះ?

អ្នកអាចបោះឆ្នោតនៅកន្លែងបោះឆ្នោតណាមួយនៅពេលបោះឆ្នោតសកល ឬបោះឆ្នោតពិសេស។ អ្នកនឹងត្រូវការចុះឈ្មោះបោះឆ្នោតពិសេស ដោយសារព័ត៌មានលម្អិតរបស់អ្នក នឹងមិនត្រូវបានបញ្ចូលក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានបោះពុម្ព ដែលត្រូវបានប្រើប្រាស់ដើម្បីចេញសន្លឹកឆ្នោតនៅកន្លែងបោះឆ្នោតឡើយ។

អ្នកនឹងត្រូវបំពេញទម្រង់បែបបទបន្ថែមមួយជាមួយនឹងសន្លឹកឆ្នោតរបស់អ្នក ដើម្បីបញ្ជាក់ក្រុមអ្នកបោះឆ្នោតដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ អ្នកមិនចាំបាច់បំពេញព័ត៌មានអំពីអាសយដ្ឋាន ឬឈ្មោះពីមុននៅលើទម្រង់បែបបទនេះឡើយ ប្រសិនបើអ្នកមិនចង់បំពេញនោះ។ ទោះយ៉ាងណាក៏ដោយ ការផ្ដល់ព័ត៌មាននេះជួយយើងអាចបញ្ជាក់ពីសិទ្ធិរបស់អ្នកក្នុងការបោះឆ្នោត។ នៅពេលអ្នកទៅដល់កន្លែងបោះឆ្នោត នឹងមានមន្ត្រីម្នាក់នៅទីនោះ ដើម្បីបង្ហាញអ្នកពីអ្វីដែលអ្នកត្រូវធ្វើ។

ដើម្បីបោះឆ្នោតនៅថ្នាក់មូលដ្ឋាន អ្នកនឹងត្រូវការស្នើសុំឲ្យមន្ត្រីទទួលបន្ទុកកិច្ចការបោះឆ្នោតនៅក្រុមប្រឹក្សាមូលដ្ឋានរបស់អ្នកផ្ញើសន្លឹកឆ្នោតឲ្យអ្នក។

**ELECTORAL COMMISSION**
TE KAITIAKI TAKE KŌWHIRI

## របៀបស្នើសុំឲ្យដាក់ឈ្មោះលើបញ្ជីមិនផ្សព្វផ្សាយ

ដើម្បីស្នើសុំដាក់ឈ្មោះលើបញ្ជីមិនផ្សព្វផ្សាយ សូមបំពេញទម្រង់បែបបទដែលមានភ្ជាប់នឹងខិតប័ណ្ណនេះ ហើយប្រគល់មកយើងវិញ៖

ប្រសិនបើអ្នកមិនទាន់ចុះឈ្មោះបោះឆ្នោតនៅឡើយ ឬអ្នកត្រូវការធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នក អ្នកក៏ត្រូវបំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោតផងដែរ។ ដើម្បីទទួលបានទម្រង់បែបបទចុះឈ្មោះបោះឆ្នោត សូមជ្រើសរើសជម្រើសមួយក្នុងចំណោមជម្រើសទាំងពីរនេះ៖

- ទូរសព្ទទៅកាន់លេខ **0800 36 76 56** ហើយយើងនឹងផ្ញើទម្រង់បែបបទចុះឈ្មោះបោះឆ្នោតទៅអ្នក
- ទាញយកទម្រង់បែបបទចុះឈ្មោះបោះឆ្នោតនៅ **vote.nz** ដើម្បីបំពេញ និងប្រគល់មកយើងវិញ។

## តើខ្ញុំត្រូវរួមបញ្ចូលព័ត៌មានគាំទ្រអ្វីខ្លះ?

អ្នកត្រូវផ្ដល់ព័ត៌មាន ដើម្បីបង្ហាញថាតើហេតុអ្វីបានជាអ្នកត្រូវការចុះឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនផ្សព្វផ្សាយនេះ។ ទាំងនេះគឺជាឧទាហរណ៍នៃប្រភេទព័ត៌មានមួយចំនួនដែលត្រូវរួមបញ្ចូល៖ (អ្នកមិនត្រូវការព័ត៌មានប្រភេទទាំងអស់នេះក្នុងការស្នើសុំនោះទេ។)

- **លិខិតដែលពន្យល់ពីមូលហេតុដែលការងារ ឬកាលៈទេសៈផ្ទាល់ខ្លួនធ្វើឲ្យអ្នកប្រឈមនឹងហានិភ័យ។ លិខិតនេះអាចបានមកពីនិយោជក មេធាវី បុគ្គលិកសង្គម អ្នកតស៊ូមតិ ឬនរណាម្នាក់ដែលតំណាងឲ្យសហគមន៍។**
- **សំណៅច្បាប់ចម្លងនៃបទបញ្ជាការពារ ដែលមានជាធរមាន ក្រោមច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារឆ្នាំ 1995 ។**
- **សំណៅច្បាប់ចម្លងនៃបទបញ្ជាហាមឃាត់សកម្មភាពបង្កអន្តរាយ ដែលមានជាធរមាន ក្រោមច្បាប់ស្ដីពីការយាយីឆ្នាំ 1997 ។**
- **ព័ត៌មានពីមន្ត្រីនគរបាល ឬមន្ត្រីកែប្រែ ពន្យល់ពីមូលហេតុដែលបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់អ្នក អាចបុរេវិនិច្ឆ័យចំពោះសុវត្ថិភាពអ្នក និងក្រុមគ្រួសាររបស់អ្នក។**

## Complete this form to apply to go on the unpublished roll.

**Full name:**

**Date of birth:**

**Contact phone number:**

**Email:**

**Address where you are enrolled to vote or have applied to enrol:**

**List the information provided to support your application:**

**✓ Please tick one of the following:**

- ☐ **I am already enrolled to vote**
- ☐ **I am not enrolled and I have enclosed a completed enrolment form**

**Signature**

**Date**

Complete and return to Electoral Commission,
**PO Box 190, Wellington 6140**

Remember to return any information that supports your application to register on the unpublished roll.

For more information visit **vote.nz**